# ជំងឺអុតស្វាយ

## អ្វីដែលអ្នកគួរដឹង

Tacoma-Pierce County
Health Department
*Healthy People in Healthy Communities*



### វីរុស varicella-zoster បង្កឱ្យមានជំងឺអុតស្វាយ។

**រោគសញ្ញា៖**

- កន្ទួលដូចពងបែក។
- គ្រុនក្ដៅ។
- ឈឺក្បាល។
- អស់កម្លាំង។
- ការបាត់បង់ចំណង់អាហារ។



### ជំងឺអុតស្វាយអាចរីករាលដាលបានយ៉ាងងាយ៖





- តាមរយៈខ្យល់។
- តាមរយៈផ្ទៃ។

**មនុស្សអាចចម្លងជំងឺអុតស្វាយ1-2ថ្ងៃមុនពេលពួកគេឡើងកន្ទួល រហូតដល់ពងបែកទាំងអស់ក្រៀមបង្កើតជាក្រមរ។**






### ការចាក់វ៉ាក់សាំងគឺជាមធ្យោបាយដ៏ល្អបំផុតក្នុងការបង្ការជំងឺអុតស្វាយ។

**អ្នកដែលមិនទាន់ចាក់វ៉ាក់សាំងគួរតែ៖**

- ជៀសវាងអ្នកដែលមានជំងឺអុតស្វាយ និងទីកន្លែងដែលមានការផ្ទុះឡើងនូវជំងឺអុតស្វាយ។
- ឧស្សាហ៍លាងដៃជាមួយសាប៊ូ និងទឹកក្ដៅឧណ្ហៗ។



### ជំងឺអុតស្វាយអាចមានគ្រោះថ្នាក់សម្រាប់អ្នកដែល៖



- ជាទារក។
- ជាក្មេងជំទង់។
- ជាមនុស្សពេញវ័យ
- ជាស្ត្រីមានផ្ទៃពោះ។
- រស់នៅជាមួយនឹងប្រព័ន្ធភាពស៊ាំខ្សោយ។

វាអាចបណ្ដាលឱ្យមានការឆ្លងមេរោគទៅខួរក្បាល រលាកសួត ឬពិការភាពពីកំណើត។

**ប្រសិនបើអ្នកទាំងនេះប្រឈមនឹងជំងឺអុតស្វាយ សូមទូរសព្ទទៅអ្នកផ្ដល់សេវាថែទាំសុខភាពភ្លាមៗ។**



### មិនទាន់ចាក់វ៉ាក់សាំងនិងប្រឈមនឹងជំងឺ? ចាក់វ៉ាក់សាំងក្នុងរយៈពេល 3-5 ថ្ងៃដើម្បីការពារឬកាត់បន្ថយហានិភ័យជំងឺ។

ប្រសិនបើអ្នកឈឺ៖

- សម្រាក។
- ទទួលទានទឹក។
- ព្យាបាលគ្រុនក្ដៅនិងអារម្មណ៍មិនស្រួលក្នុងខ្លួនតាមការចាំបាច់ ។ កុំផ្ដល់ថ្នាំអាស្ពីរីនដល់កុមារឱ្យសោះ។



ស្វែងយល់បន្ថែមតាមរយៈ:
**cdc.gov/chickenpox**

Communicable Disease Control | ខែមីនា ឆ្នាំ 2024 | Khmer
3629 S. D St. | Tacoma, WA 98418 | (253) 649-1413 | tpchd.org

# ជំងឺអុតស្វាយ

## សំណួរដែលត្រូវបានសាកសួរជាញឹកញាប់

Tacoma-Pierce County
Health Department
Healthy People in Healthy Communities

### សំណួរដែលត្រូវបានសាកសួរជាញឹកញាប់

អត់នោះទេ។ កុមារនៅសហរដ្ឋអាមេរិកបានចាប់ផ្តើមចាក់វ៉ាក់សាំងជំងឺអុតស្វាយតាំងពីឆ្នាំ 1995 មកម្លេះ។ ចាប់តាំងពីពេលនោះមក ករណីជំងឺអុតស្វាយបានថយចុះចំនួន 97%។ ប្រទេសជាច្រើនបានណែនាំវ៉ាក់សាំងជំងឺអុតស្វាយដល់កុមារ ពីព្រោះការចាក់វ៉ាក់សាំងមានសុវត្ថិភាពជាជាងការកើតជំងឺនេះ។

### តើវ៉ាក់សាំងជំងឺអុតស្វាយមានផលរំខានអ្វីខ្លះ?

ផលរំខានទូទៅបំផុតគឺការចុក ការឈឺចាប់ ការឡើងក្រហម និងការហើមនៅកន្លែងចាក់ថ្នាំ។ អាការៈទាំងនេះជាធម្មតានឹងបាត់ទៅវិញក្នុងរយៈពេលប៉ុន្មានថ្ងៃប៉ុណ្ណោះ។

### ហេតុអ្វីបានជាយើងចាំបាច់ត្រូវការវ៉ាក់សាំងជំងឺអុតស្វាយ?

កុមារភាគច្រើនដែលកើតជំងឺអុតស្វាយជាសះស្បើយបន្ទាប់ពីជំងឺកម្រិតស្រាល។ ប៉ុន្តែជំងឺកម្រិតធ្ងន់ធ្ងរក៏អាចកើតឡើងដែរ។ ជំងឺអុតស្វាយអាចបណ្តាលឱ្យមានការឆ្លងមេរោគទៅខួរក្បាល រលាកសួត ការឆ្លងមេរោគក្នុងចរន្តឈាម និងពិការភាពពីកំណើត។

មុនពេលមានវ៉ាក់សាំង មានមនុស្សប្រហែលជា 4 លាននាក់នៅក្នុងសហរដ្ឋអាមេរិកបានកើតជំងឺអុតស្វាយជារៀងរាល់ឆ្នាំ ដែលច្រើនជាង 10,000 នាក់បានទៅមន្ទីរពេទ្យ ហើយច្រើនជាង 100 នាក់បានបាត់បង់ជីវិត។

### តើអ្នកណាដែលប្រឈមនឹងជំងឺកម្រិតធ្ងន់ធ្ងរបំផុតដោយសារជំងឺអុតស្វាយ?

ជំងឺកម្រិតធ្ងន់ធ្ងរពីជំងឺអុតស្វាយគឺជារឿងទូទៅបំផុតចំពោះអ្នកដែលមិនមានភាពស៊ាំ (មិនបានចាក់វ៉ាក់សាំង និងមិនដែលមានជំងឺនេះ) ជាពិសេសទារក ក្មេងជំទង់ មនុស្សពេញវ័យ និងអ្នកដែលមានផ្ទៃពោះ ឬមានប្រព័ន្ធភាពស៊ាំខ្សោយ។

### តើមនុស្សគួរចាក់វ៉ាក់សាំងជំងឺអុតស្វាយនៅពេលណា?

រដ្ឋវ៉ាស៊ីនតោន តម្រូវឱ្យកុមារចាក់វ៉ាក់សាំងជំងឺអុតស្វាយ មុនពេលដែលពួកគេចូលសាលារៀន ឬចូលមណ្ឌលថែទាំកុមារ។

មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺឆ្លង (CDC) ណែនាំឱ្យកុមារទទួលបានការចាក់វ៉ាក់សាំងជំងឺអុតស្វាយដូសទីមួយនៅអាយុ 12 ខែ និងចាក់ដូសលើកទី 2 នៅអាយុ 4-6 ឆ្នាំ។

អ្នកដែលមានអាយុពី 7 ឆ្នាំឡើងទៅដែលមិនមានភាពស៊ាំអាចទទួលបានវ៉ាក់សាំងចំនួន 2 ដូស។

អ្នកដែលមិនមានភាពស៊ាំនិងប្រឈមនឹងជំងឺអុតស្វាយអាចចាក់វ៉ាក់សាំងក្នុងរយៈពេល3-5ថ្ងៃដើម្បីការពារ ឬកាត់បន្ថយហានិភ័យជំងឺ។

អ្នកដែលកើតមុនឆ្នាំ 1980 ត្រូវបានគេចាត់ទុកថាមានភាពស៊ាំហើយដោយសារតែពួកគេទំនងជាធ្លាប់កើតជំងឺនេះរួចហើយ។

### តើខ្ញុំអាចដឹងដោយរបៀបណាថាកូនរបស់ខ្ញុំបានចាក់វ៉ាក់សាំងជំងឺអុតស្វាយរួចហើយនោះ?

ស្វែងរកកំណត់ត្រាការចាក់វ៉ាក់សាំងរបស់កូនអ្នកនៅ myirmobile.com ឬទាក់ទងអ្នកផ្តល់សេវាថែទាំសុខភាពរបស់កូនអ្នក

### តើកូនរបស់ខ្ញុំអាចទទួលការចាក់វ៉ាក់សាំងជំងឺអុតស្វាយបាននៅកន្លែងណា?

កូនរបស់អ្នកអាចទទួលការចាក់វ៉ាក់សាំងជំងឺអុតស្វាយ នៅការិយាល័យរបស់អ្នកផ្តល់សេវាថែទាំសុខភាព ឬនៅឱសថស្ថាន។ ស្វែងរកទីតាំងចាក់វ៉ាក់សាំងដោយឥតគិតថ្លៃផ្សេងទៀតនៅ tpchd.org/kidsvax។

### តើមានថ្នាំព្យាបាលជំងឺអុតស្វាយដែរឬទេ?

អ្នកជំងឺភាគច្រើនដែលកើតជំងឺអុតស្វាយនឹងត្រូវការតែការព្យាបាលគ្រុនក្តៅ និងអារម្មណ៍មិនស្រណុកក្នុងខ្លួនតែប៉ុណ្ណោះ។ កុំផ្តល់ថ្នាំអាស្ពីរីនដល់កុមារឱ្យសោះ។

មនុស្សមួយចំនួនដែលមានហានិភ័យខ្ពស់ប្រឈមនឹងជំងឺកម្រិតធ្ងន់ធ្ងរពីជំងឺអុតស្វាយៈ ទារក ក្មេងជំទង់ មនុស្សពេញវ័យ និងអ្នកដែលមានផ្ទៃពោះ ឬមានប្រព័ន្ធភាពស៊ាំខ្សោយ។ ប្រសិនបើអ្នកទាំងនេះប្រឈមនឹងជំងឺអុតស្វាយ សូមទូរសព្ទទៅអ្នកផ្តល់សេវាថែទាំសុខភាពភ្លាមៗ។ អ្នកផ្តល់សេវាថែទាំសុខភាពអាចចេញវេជ្ជបញ្ជាថ្នាំប្រឆាំងមេរោគជូនបាន។

ស្វែងយល់បន្ថែមតាមរយៈ:
**cdc.gov/chickenpox**